# <u>សេចក្តីប្រកាសរបស់ UNESCO ស្តីពីបណ្ណាល័យសាធារណៈ ១៩៩៤</u>

សេរីភាព វិបុលភាព និងការអភិវឌ្ឍន៍របស់សង្គម និងបុគ្គលគឺជាតំលៃជាមូលដ្ឋានរបស់មនុស្ស ។ ពួកគេអាចទទួលបានទាំងអស់នេះលុះត្រាតែពួកគេជាប្រជាជនដែលអាចទទួលបានពត៌មានគ្រប់គ្រាន់ដើម្បីអនុវត្តសិទ្ធិ និងធ្វើសកម្មភាពរបស់ពួកគេក្នុងសង្គម (ការចូលរួមក្នុងន័យកសាង និងការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យគឺវាពឹងផ្អែកទៅលើការអប់រំ ដ៏គួរអោយពេញចិត្ត រួមទាំងការទទួលបាននូវចំណេះវិជ្ជាដោយសេរី និងគ្មានព្រំដែនតាមរយៈវប្បធម៌និងពត៌មាន) ។

បណ្ណាល័យសាធារណៈដែលជាកន្លែងផ្តល់ចំណេះវិជ្ជាក្នុងតំបន់ផ្តល់លក្ខណៈជាមូលដ្ឋានសំរាប់ការរៀនសូត្រមួយជីវិត ការសំរេចចិត្តដោយខ្លួនឯង ការអភិវឌ្ឍន៍វប្បធម៌របស់បុគ្គល និងសង្គម ។

សេចក្តីប្រកាសនេះ ប្រកាសថាជំនឿរបស់ UNESCO ចំពោះបណ្ណាល័យសាធារណៈជាកំលាំងសំរាប់ការអប់រំ វប្បធម៌ និងព៌តមាន ហើយជាភ្នាក់ងារដ៏សំខាន់សំរាប់ជំរុញសន្តិភាព និងសុខមាលភាពផ្លូវចិត្តតាមរយៈសតិរបស់មនុស្សប្រុស និងមនុស្សស្រី ។

ដូច្នេះហើយទើបបានជា UNESCO ជំរុញអោយប្រទេសជាតិ និងរដ្ឋាភិបាលមូលដ្ឋានគាំទ្រ និង ចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍ដល់អ្នកប្រើប្រាស់ជាសាធារណៈ ។

## <u>បណ្ណាល័យសាធារណៈ</u>

បណ្ណាល័យសាធារណៈគឺជាមជ្ឈមណ្ឌលពត៌មានក្នុងតំបន់ ហើយមានចំណេះវិជ្ជា និងពត៌មានគ្រប់បែបយ៉ាងសំរាប់អ្នកប្រើប្រាស់ ។ សេវាកម្មរបស់បណ្ណាល័យសាធារណៈត្រូវបានផ្តល់ភាពស្មើគ្នាជាមូលដ្ឋានដោយមិនគិតពីអាយុ ភេទ សាសនា ជនជាតិ ភាសា ឬក៏ឋានៈក្នុងសង្គមអ្វីឡើយ ។ សេវាកម្ម និងសំភារៈពិសេសត្រូវបានផ្តល់ចំពោះ ជនទាំងឡាយណា ដែលមិនអាចប្រើប្រាស់សេវាកម្ម និងសំភារៈធម្មតាដោយសារមូលហេតុណាមួយ ឧទាហរណ៍ មានបញ្ហាខាងភាសា ជនជាតិភាគតិច ជនពិការ អ្នកនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរឃុំឃាំង ។

គ្រប់ក្រុមទាំងអស់ត្រូវតែស្វែងរកសំភារៈដែលទាក់ទងទៅនឹងតម្រូវការរបស់ពួកគេ ។ ការប្រមូលផ្តុំ និងសេវាកម្មត្រូវតែមានពត៌មានសមរម្យ បច្ចេកទេសទំនើបៗ រួមទាំងលក្ខខណ្ឌក្នុងតំបន់គឺជាមូលដ្ឋាន ។ សំភារៈត្រូវឆ្លុះបញ្ចាំងពីនិន្នាការ និងការអភិវឌ្ឍន៍របស់សង្គមរួមទាំងអនុស្សាវរីយ៍នៃការខិតខំប្រឹងប្រែង និងការស្រមើស្រមៃរបស់មនុស្ស ។

ការប្រមូលផ្តុំ និងសេវាកម្មមិនត្រូវស្ថិតនៅក្រោមសម្ពាធមនោគមវិជ្ជា នយោបាយ សាសនា ឬ ពាណិជ្ជកម្មណាមួយឡើយ ។

## <u>បេសកកម្មរបស់បណ្ណាល័យសាធារណៈ</u>

បេសកកម្មសំខាន់ៗខាងក្រោមដែលទាក់ទងនឹងពត៌មាន អក្សរសាស្ត្រ អប់រំ វប្បធម៌ គឺជាស្នូលនៃសេវាកម្មរបស់បណ្ណាល័យសាធារណៈ

១- បង្កើត និងពង្រឹងទំលាប់ការអានសៀវភៅរបស់កុមារតាំងពីវ័យកុមារភាព
២- គាំទ្រទាំងស្វ័យសិក្សា និងការអប់រំជាផ្លូវការគ្រប់កំរិត
៣- ផ្តល់ឱកាសសំរាប់ការអភិវឌ្ឍន៍បុគ្គល
៤- ជំរុញអោយមានរូបបារម្មណ៍ និងការច្នៃប្រឌិតរបស់កុមារ និងក្មេងជំទង់
៥- លើកកំពស់ការយល់ដឹងពីកេរមរតកវប្បធម៌
៦- ផ្តល់អោយមានការសន្ទនាស្តីពីវប្បធម៌ និងការយោគយល់ដល់វប្បធម៌ផ្សេងៗគ្នា
៧- បង្កើនអោយមានការសន្ទនាអន្តរវប្បធម៌ និងការយោគយល់ដល់វប្បធម៌ផ្សេងៗគ្នា
៨- គាំទ្រប្រពៃណី ដែលបន្តពីមាត់មួយ ទៅមាត់មួយ
៩- ធានាអោយមានពត៌មានដល់ប្រជាជន
១០- ផ្តល់សេវាកម្មពត៌មានសមរម្យដល់សហគ្រាសក្នុងស្រុក សហគមន៍ និងក្រុមដែលមានចំណាប់អារម្មណ៍
១១- ជួយសំរួលដល់ការអភិវឌ្ឍន៍ខាងពត៌មាន និងជំនាញកុំព្យូទ័រប្រើប្រាស់
១២- គាំទ្រ និងចូលរួមក្នុងសកម្មភាព និងកម្មវិធីអក្ខរកម្មដល់មនុស្សគ្រប់វ័យ ហើយមានការផ្តួចផ្តើមសកម្មភាពដូចនេះ បើសិនមានការចាំបាច់

## មូលនិធិ ច្បាប់ បណ្តាញការងារ

- ជាគោលការណ៍ បណ្ណាល័យសាធារណៈត្រូវផ្តល់សេវាកម្មដោយឥតគិតថ្លៃ ។ បណ្ណាល័យសាធារណៈ គឺជាការទទួលខុសត្រូវរបស់អាជ្ញាធរតំបន់ និងជាតិ ។ បណ្ណាល័យនេះត្រូវទទួលការគាំទ្រពីច្បាប់ណាមួយ ហើយឧបត្ថម្ភថវិកាពីសំណាក់រដ្ឋាភិបាលតំបន់ និងជាតិ ហើយបណ្ណាល័យនេះត្រូវតែជាសមាសភាគនៃយុទ្ធសាស្ត្ររយៈពេលវែងដើម្បីវប្បធម៌ ការផ្តល់ពត៌មាន អក្ខរកម្ម និងការអប់រំ ។
- ដើម្បីធានាអោយមានការសហប្រតិបត្តិការ និងការសំរបសំរួលរវាងបណ្ណាល័យទូទាំងប្រទេស ច្បាប់ និងផែនការយុទ្ធសាស្ត្រ ត្រូវតែកំនត់ នឹងធ្វើអោយប្រសើរនូវបណ្តាញបណ្ណាល័យទូទាំងប្រទេស ដោយពឹងផ្អែកលើសេវាកម្មស្តង់ដាដែលបានយល់ព្រម ។
- បណ្តាញបណ្ណាល័យសាធារណៈត្រូវតែធ្វើឡើងអោយទាក់ទងទៅនឹងការស្រាវជ្រាវក្នុងតំបន់ ប្រទេស បណ្ណាល័យពិសេសព្រមទាំងបណ្ណាល័យនៅក្នុងសាលា និងមហាវិទ្យាល័យ ។

## ការប្រតិបត្តិ និងគ្រប់គ្រង

- ត្រូវមាននយោបាយច្បាស់លាស់ស្តីពី កម្មវត្ថុ អាទិភាពសេវាកម្មដែលទាក់ទងទៅនឹងតម្រូវការរបស់សហគមន៍ ។ បណ្ណាល័យសាធារណៈត្រូវតែរៀបចំអោយមានប្រសិទ្ធិភាព និងការប្រតិបត្តិតាមរយៈស្តង់ដាឯកទេសត្រឹមត្រូវ ។

- ត្រូវធានាអោយប្រាកដនូវកិច្ចសហប្រតិបត្តិការជាមួយដៃគូដែលទាក់ទង ឧទាហរណ៍ ក្រុមអ្នកប្រើប្រាស់ ក្រុមឯកទេសនៅតាមមូលដ្ឋាន តំបន់ ថ្នាក់ជាតិ និងអន្តរជាតិផងដែរ ។
- ធ្វើយ៉ាងណាអោយសមាជិកសហគមន៍ទាំងអស់អាចទទួលបាននូវសេវាកម្ម ។ វាតម្រូវអោយអាគារបណ្ណាល័យស្ថិតនៅកន្លែងមួយសមស្រប ភាពងាយស្រួលក្នុងការអាន និងសិក្សារួមទាំងបច្ចេកវិទ្យាសមស្របនឹងរយៈពេលបើកបណ្ណាល័យគ្រប់គ្រាន់ដែលធ្វើអោយមានការងាយស្រួលដល់អ្នកប្រើប្រាស់ ។
- បណ្ណាល័យសាធារណៈត្រូវតែសម្របទៅនឹងតម្រូវការខុសគ្នានៅក្នុងតំបន់ ហើយការអប់រំបន្តបន្ទាប់របស់បណ្ណារក្ស គឺជាអ្វីដែលចាំបាច់ដើម្បីធ្វើអោយមានសេវាកម្មដ៏សមរម្យ ។
- ត្រូវមានកម្មវិធីអប់រំអ្នកប្រើប្រាស់ដើម្បីអោយពួកគេអាចមានលទ្ធភាពទទួលបានផលប្រយោជន៍ពីឯកសារទាំងឡាយ ។/